**ដំណឹងថ្មីៗអំពីគម្រោងដោះស្រាយមកលើជម្ងឺ កូវីដ**

ក្នុងគ្រាវិស្សមកាលរដូវរងាថ្មីៗកន្លងមក  មានអភិបាលប្រចាំរដ្ឋ កាលីហ្វ័រញ៉ា គឺលោក Gavin Newsom បានបញ្ចេញជាគម្រោងព្រាងទុកមួយ ហៅ សុវត្ថិភាពនៅតាមសាលារៀនសម្រាប់យើងទាំងអស់  – Safe Schools for All ។ គោលដៅអំពីគម្រោង  គឺគាំទ្រជាបន្ថែមមកលើសាលារៀនទាំងអស់ក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដើម្បីបញ្ជូនសិស្សត្រឡប់ចូលរៀនក្នុងថ្នាក់វិញអោយបានយ៉ាងឆាប់រហ័ស  ផ្តើមពីកម្រិតថ្នាក់ Transitional Kindergarten ទៅថ្នាក់ទី2 ដោយបូកបន្ថែមជាកម្រិតថ្នាក់ផ្សេងៗជាបន្តបន្ទាប់ទៅទៀតនៅតាមសាលាបឋមសិក្សា ។

យើងបានពិនិត្យអំពីគម្រោងព្រាងទុកយ៉ាងដិតដល់  និង រួមជាមួយក្រសួងអប់រំ ឌីស្រ្ទីគ ផ្សេងៗទៀត គឺយើងទាំងអស់គ្នាបានលើកផ្តល់ជាមតិទៅកាន់រដ្ឋវិញ ដើម្បីសុំអោយធ្វើការយកចិត្តទុកដាក់ដោះស្រាយយ៉ាងច្បាស់លាស់មកលើសេចក្តីត្រូវការនៃសិស្ស  និង បុគ្គលិករបស់យើង ។ ក្នុងគ្រាដែលជម្ងឺកំពុងតែរាលដាលកើនឡើងយ៉ាងខ្លាំងនៅតាមតំបន់  និង ទូទាំងប្រទេស គឺឥឡូវនេះ កម្មវិធីបង្ហាត់មេរៀនភាគច្រើនរបស់យើងនឹងនៅតែធ្វើតាមរយៈ អនឡាញ ដែលបន្តរហូតយ៉ាងតិចណាស់ទៅដល់ថ្ងៃទី1  ខែមិនា ដូចបានប្រកាសជូនរួចមកហើយនៅមុនពេលវិស្សមកាលរដូវរងា  ។

គោលដៅរបស់យើង គឺបើកសាលារៀនឡើងវិញសម្រាប់បង្ហាត់កម្មវិធីនៅតាមថ្នាក់  ដែលពេញទៅដោយសុវត្ថិភាព  ដូចបានបញ្ជាក់រួចមកហើយនៅក្នុង គម្រោងបើកសាលារៀន និង សុវត្ថិភាពសម្រាប់ឆ្នាំសិក្សា 2020-21 នៅតាមតំបន់របស់យើង ដែលអាចបើកមើលបាននៅក្នុង lbschools.net ។ យើងបានប្រុងទុកជាស្រេចហើយអំពីការប្រើតាមគម្រោងនោះ  នៅពេលណាជម្ងឺ កូវីដ មានភាពស្រកចុះ ដោយបានទិញទុកប្រដាប់ប្រើការពារខ្លួន  ដូចជាៈ គម្របមុខ ក្រដាសជូតបង្ក្រាបមេរោគ ម៉ាស៊ីនស្ទង់វាស់កំដៅខ្លួន ប្រដាប់ជូតសំអាតដៃ និង អ្វីជាបន្ថែម តាមរយៈប្រើជំនួយថវិការពីរដ្ឋាភិបាលជាតិ  ហៅ CARES ACT ដែលបានទទួលមកសម្រាប់ប្រើដោះស្រាយបន្ទូរបញ្ហាទាក់ទងជម្ងឺ  កូវីដ ។

យើងមានជំនឿថា គម្រោងព្រាងទុករបស់រដ្ឋសម្រាប់រក្សាសុវត្ថិភាពនៅតាមសាលារៀន  គឺជាចំណុចផ្តើមមួយដ៏ល្អ ដោយចង់បានក្បួនណែនាំកាន់តែច្បាស់លាស់ជាបន្ថែមទៀតសម្រាប់ប្រើនៅតាមរដ្ឋ  កាលីហ្វ័រញ៉ា ទាំងមូលនៅពេលបញ្ជូនសិស្សត្រឡប់ចូលរៀនវិញ  ។ យើង និង ក្រសួងអប់រំ ឌីស្រ្ទីគ ផ្សេងៗទៀតនៅតែបន្តការផ្តល់ជាមតិសម្រាប់សុំអោយមានជាខ្នាតគំរូយ៉ាងច្បាស់លាស់សម្រាប់ប្រើដោះស្រាយជម្ងឺ  កូវីដ នៅតាមសាលារៀន និង សុំអោយចេញបញ្ជីសម្រាប់ប្រើតាមជាមួយការបើកបង្ហាត់កម្មវិធីនៅតាមថ្នាក់ឡើងវិញ  នៅពេលណាខ្នាតគំរូនោះបានរៀបចំទៅយ៉ាងពិតប្រាកដមែន ។ នាយកដឹកនាំថ្នាក់លើក្នុងក្រសួងអប់រំ  ឌីស្រ្ទីគ រួមទាំងសមាជិកគណៈកម្មការសាលារៀនរបស់យើងផង  ក៏បានលើកផ្តល់ជាមតិដែរអំពីការស្នើសុំជំនួយជាបន្តបន្ទាប់  និង ការបង្កើតច្បាប់យ៉ាងច្បាស់លាស់មកពីរដ្ឋ  និង រដ្ឋាភិបាលជាតិសម្រាប់ប្រើដោះស្រាយមកលើផ្នែកសុវត្ថិភាព  នៅពេលយើងទាំងអស់គ្នាត្រឡប់ចូលសាលារៀនវិញ  ។

ក្នុងពេលជាមួយគ្នានេះដែរ  គឺយើងនឹងបន្តការចែកផ្តល់ជាជំនួយ  ដែលធ្លាប់តែបានធ្វើមកក្នុងគ្រាឆ្លងកាត់ជម្ងឺរាលដាល  ហើយយើងនឹងគាំទ្រមកលើកម្មវិធីរៀនពីចម្ងាយទៅតាមសមត្ថភាពល្អពិសេស  ដែលអាចធ្វើទៅបាន ។

យើងសង្ឃឹមថា ឆ្នាំ2021 នឹងនាំមកជាសុវត្ថិភាព  និង សុខភាពល្អកាន់តែប្រសើរ ។

ដោយសេចក្តីអំណរគុណ...

បណ្ឌិត Jill Baker, Ed. D
អគ្គនាយកសាលារៀន